# ទស្សនៈអ្នកស្រាវជ្រាវចំពោះសិលាចារឹកវ៉ូកាញ់ C.៤០ (ភាគ១)

## ១- ព័ត៌មានទូទៅ

វ៉ូកាញ់ ជាឈ្មោះសិលាចារឹកមួយ ដ្បិតតែមិនស្ថិតនៅលើទឹកដីកម្ពុជាក្តី ក៏អ្នកសិក្សារៀនសូត្រខ្មែរជាទូទៅ បានស្គាល់ឈ្មោះសិលាចារឹកនេះស្ទើរតែគ្រប់គ្នា។ ការរកឃើញ ទីតាំងរកឃើញ និងខ្លឹមសារសិលាចារឹកនេះ ត្រូវបានអ្នកសិក្សាខ្មែរមួយចំនួនប្រើប្រាស់ជាភស្តុតាងបញ្ជាក់អំពីចំណាស់និងវិសាលភាពនៃទឹកដីអាណាចក្រហ៊្វូណាន ព្រមទាំងវត្តមានពុទ្ធសាសនាដែលផ្សព្វផ្សាយនៅដែនដីអាស៊ីអាគ្នេយ៍ដីគោក ឬដែនដីសុវណ្ណភូមិ[1]។ ប្រការនេះហើយ ទើបនាំឲ្យសិលាចារឹកនេះល្បីសុសសាយ និងស្គាល់យ៉ាងទូលាយ ដោយមានបញ្ចូលក្នុងកម្មវិធីសិក្សាផ្លូវការផង។ យ៉ាងនេះក្តី ប្រភពនៃការសិក្សាសិលាចារឹកនេះ ផ្តើមចេញពីអ្នកសិក្សាបស្ចិមប្រទេស និងបន្តជដែកគ្នានៅក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវអំពីឥទ្ធិពលឥណ្ឌានៅចុងបូព៌ា ស្ទើរតែមិនដាច់ តាំងពីចុងស.វ.ទី១៨ មកដល់ទ.ស.ទី១នៃស.វ.ទី២១នេះ។

នៅក្នុងការសិក្សាស្រាវជ្រាវកន្លងមក អ្នកសិក្សាជាច្រើនបានបញ្ចេញគំនិតទស្សនៈនៅក្នុងស្នាដៃរបស់ខ្លួនតាមរយៈអត្ថបទនិងសៀវភៅ ដើម្បីពន្យល់បកស្រាយអំពីអាយុកាល លក្ខណៈសាសនា និងភាពជាម្ចាស់របស់សិលាចារឹកនេះ យ៉ាងសម្បូរបែប។ ថ្វីដ្បិតតែការសិក្សាទាំងនោះ មានការប្រែប្រួលយ៉ាងណាក្តី ក៏ខ្មែរហាក់ចាប់ជាប់ពុំលែង ត្រឹមតែទស្សនៈថា សិលាចារឹកវ៉ូកាញ់នេះ ជារបស់ខ្មែរដើម (ហ៊្វូណាន) មានចំណាស់រវាងស.វ.ទី២-៣ និងជាភស្តុតាងនៃការផ្សាយព្រះពុទ្ធសាសនាមកកាន់ដែនសុវណ្ណភូមិ។

អត្ថបទនេះ នឹងលើកបង្ហាញអំពីប្រវត្តិនៃការសិក្សាសិលាចារឹកវ៉ូកាញ់ ដោយរំលេចនូវទស្សនៈនិងហេតុផលជាគោលធំៗ ដែលអ្នកសិក្សាស្រាវជ្រាវកន្លងមកបានចេញផ្សាយក្នុងអត្ថបទនិងសៀវភៅនានា។ សេចក្តីសង្ខេបគំនិតទស្សនៈទាំងនេះ នឹងចូលរួមចំណែកក្នុងការពង្រីកការយល់ដឹងទូលាយអំពីសិលាចារឹកវ៉ូកាញ់ លើសពីអ្វីដែលហាក់ដូចជាធ្លាប់ឮតៗគ្នាមក។

[1] ប៉ាង ខាត់, *ពុទ្ធសាសនា ២៥០០*, ពុទ្ធសាសនបណ្ឌិត្យ (ពុទ្ធសាសនបណ្ឌិត្យ, ១៩៥៧)។

អត្ថបទដោយ៖ ហ៊ិន ឈុនតេង

## ២- ប្រវត្តិនៃការរកឃើញ និងព័ត៌មានសិលាចារឹក

សិលាចារឹកវ៉ូកាញ់ ចុះក្នុងបញ្ជីសារពើភណ្ឌសិលាចារឹកចាម្ប៉ លេខC.៤០ បានប្រទះឃើញនាឆ្នាំ១៨៨៥ នៅកណ្តាលវាលស្រែមួយ ស្ថិតក្នុងភូមិវ៉ូកាញ់ (Võ Cạnh) ឃុំវិញត្រុង (Vĩnh Trung) ស្រុកឌៀនខាញ់ (Diên Khánh) ក្រុងញ៉ាត្រាង (Nha Trang) ខេត្តខាញ់ហ័រ (Khánh Hòa) ប្រទេសវៀតណាម[២]។ នៅឆ្នាំ១៩០១ គេរកឃើញទួលប្រាសាទឥដ្ឋមួយក្បែរនោះ[៣]។ បន្ទាប់មកនៅឆ្នាំ១៩១០ សាលាបារាំងចុងបូព៌ាប្រទេស (EFEO) បានផ្ទេរសិលាចារឹកនេះ ទៅរក្សាទុកនៅសារមន្ទីរ ល្វី ហ្វីណូត៍ ដែលបច្ចុប្បន្នជាសារមន្ទីរប្រវត្តិសាស្ត្រជាតិវៀតណាម ក្នុងរដ្ឋធានីហាណូយ ប្រទេសវៀតណាម គឺរក្សាទុកនៅទីនោះរហូតមកដល់បច្ចុប្បន្ន[៤] និងបានចុះក្នុងបញ្ជីបេតិកភណ្ឌជាតិ តាមសេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រីលេខ២៥៩៩/QĐ-TTg ចុះថ្ងៃទី៣០/១២/២០១៣[៥]។

សិលាចារឹកនេះ ចារជាភាសាសំស្ក្រឹត បទវសន្តតិលកា និងអាចមានបទសាទ៌ូលវិក្រីឌិតនៅបន្ទាត់ទី១៣[៦]។ ជាទូទៅអ្នកស្រាវជ្រាវយល់ថាចារលើផ្ទៃចំនួន២ ប៉ុន្តែក្រោយមកលោក ក្លូដ ហ្សាក់ បានអះអាងថាជាចារលើផ្ទៃចំនួន៣ ដែលផ្ទៃទី៣នោះនៅសល់អក្សរបន្តិចបន្តួចប៉ុណ្ណោះ[៧]។ ថ្មចារសិលាចារឹកនេះ ជាថ្មក្រានីត (ឯកសារខ្លះថាជាថ្មភក់) មានកម្ពស់២៧០ស.ម. បន្ទារ៨០ស.ម. កម្រាស់១១០ស.ម.[៨] គឺជាថ្មដុលធម្មជាតិរាងស៊ីឡាំងសម្ផិតសម្អាតតែផ្ទៃខាងមុខប៉ុណ្ណោះឲ្យរាបស្មើ រីឯផ្ទៃផ្សេងទៀត នៅរក្សាលក្ខណៈធម្មជាតិដដែល។ ចំណែកផ្ទៃចារអត្ថបទ មានកម្ពស់ប្រហែល១៤០ស.ម. និងមានកម្ពស់តួអក្សរជា

---

[២] “Bảo tàng Lịch sử Quốc gia”, accessed 27 November 2025, https://baovatquocgia.baotangso.com/bao-vat/bia-vo-canh; Louis Finot, “Notes d’épigraphie”, *Bulletin de l’École française d’Extrême-Orient* 15, no. 1 (1915): 1–135, https://doi.org/10.3406/befeo.1915.5229; Abel Bergaigne, *Inscriptions Sanscrites de Campa et du Cambodge* (Imprimerie nationale, 1893).

[៣] Finot, “Notes d’épigraphie”, 1915.

[៤] Ian Glover and Peter S Bellwood, *Southeast Asia: from Prehistory to History* (Psychology Press, 2004).

[៥] “Bảo tàng Lịch sử Quốc gia”.

[៦] Anton O Zakharov, “A Note on the Date of the Vo-canh Stele”, *South East Asian Review* 35 (2010): 17–21.

[៧] Claude Jacques, “Notes sur la stèle de Vo-çanh”, *Bulletin de l’École française d’Extrême-Orient* 55, no. 1 (1969): 117–24, https://doi.org/10.3406/befeo.1969.4857.

[៨] “Bảo tàng Lịch sử Quốc gia”.

មធ្យម០,៤ស.ម.[៩]។ អត្ថបទចារសរុបមានចំនួន១៥បន្ទាត់ ប៉ុន្តែអត្ថបទផ្នែកខាងលើចាប់ពីបន្ទាត់ទី១ដល់បន្ទាប់ទី៥សឹករេចរិលយ៉ាងខ្លាំង ដែលជាហេតុនាំឲ្យមិនអាចអានអត្ថបទនោះយល់បាន[១០]។

## ៣- អត្ថន័យសិលាចារឹក

អត្ថន័យសិលាចារឹកនេះ បានចាប់ផ្ដើមបកប្រែដោយអ្នកស្រាវជ្រាវបារាំងតាំងពីឆ្នាំ ១៨៩៣ ជាហូរហែរហូតមក និងបកប្រែមកជាភាសាខ្មែរដោយព្រះភិក្ខុ ប៉ាង ខាត់ ចុះផ្សាយនៅក្នុងឆ្នាំ១៩៥៧-១៩៥៨។ នៅទីនេះ នឹងលើកយកអត្ថបទបកប្រែរបស់ព្រះភិក្ខុ ប៉ាង ខាត់[១១] ដោយផ្ទៀងផ្ទាត់ជាមួយនឹងការបកប្រែរបស់លោក Karl-Heinz Golzio[១២]។

**បន្ទាត់១-បន្ទាត់៥** ដាច់រលុប...

**ប.៦** សេចក្ដីករុណាចំពោះប្រជានិករទាំងឡាយ...

**ប.៧** ប្រថមជ័យ...

**ប.៨-៩** នាថ្ងៃពេញបូណ៌មី(?) មានព្រះរាជបញ្ជាហើយដោយព្រះវររាជាក្នុងទីជំនុំថា ចូរអ្នកទាំងឡាយ ក្រេបនូវទឹកអម្រឹត ពោលគឺព្រះរាជបន្ទូលនៃព្រះរាជាទាំងឡាយ។

**ប.១០-១៥** ព្រះរាជា...ជារាជកុលនៃព្រះបាទស្រីមារ ទ្រង់ជាទីត្រេកត្រអាលគាប់ហឫទ័យនៃវង្សព្រះស្រីមារ ហើយទ្រង់ឈ្វេងយល់ច្បាស់នូវគតាគតិធម៌ គឺដំណើរអន្ទោលស្លាប់កើតនៃមនុស្សលោក បានប្រថាប់ឰដ៏សិង្ហាសនៈ ហើយទ្រង់បានបើកនូវព្រះបន្ទូលសូរសីហនាទ ក្នុងកណ្ដាលជំនុំញាតិរបស់ទ្រង់ ដើម្បីជាប្រយោជន៍ដល់ប្រជាជនទាំងឡាយ បន្ទាប់ពីបានបំពេញហឫទ័យនៃបុត្រា បងប្អូន និងញាតិទាំងឡាយនូវទ្រព្យសម្បត្តិទាំងឡាយយ៉ាងដូច្នេះថា៖ ទ្រព្យទាំងឡាយ គឺប្រាក់ក្ដី មាសក្ដី សង្ខារិមក្ដី អសង្ខារិមក្ដី និងឃ្លាំង(ធញ្ញជាតិ)ក្ដី ដែលជារបស់អញ អញសូមឧទ្ទិសចំពោះអ្នកជាទីស្រឡាញ់និង

---

[៩] Finot, "Notes d'épigraphie", 1915.

[១០] Golzio Karl-Heinz, *Inscriptions of Campa*, Berichte Aus Der Orientalistik (Shaker Verlag, 2004), 1–2.

[១១] ប៉ាង, ពុទ្ធសាសនា ២៥០០។

[១២] Karl-Heinz, *Inscriptions of Campa*.

អ្នកនៅក្បែរអញៗ នេះជាអាជ្ញារបស់អញៗ ចូរព្រះរាជាក្នុងអនាគតទាំងឡាយ គោរព តាមអាជ្ញានេះៗ អាមាត្យដ៏អង់អាចរបស់អញ (ឬអាមាត្យឈ្មោះវីរ) ដឹងនូវប្រការនេះ...។

## ៤- ទស្សនៈអំពីកាលបរិច្ឆេទសិលាចារឹក

អត្ថបទសិលាចារឹកវ៉ូកាញ់ ពុំមានចុះកាលបរិច្ឆេទនោះទេ ដែលក្លាយជាបញ្ហាចោទ នៅក្នុងការកំណត់អាយុកាលសិលាចារឹកនេះមិនទាន់ដាច់ស្រឡះ រហូតមកដល់បច្ចុប្បន្ន នេះៗ សិលាចារឹកនេះ អ្នកស្រាវជ្រាវបានកំណត់អាយុកាលចន្លោះពីស.វ.ទី២រហូតដល់ ស.វ.ទី៤ ដោយប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា។

វិធីសាស្ត្រសំខាន់ៗនៅក្នុងការកំណត់អាយុកាលមានដូចខាងក្រោម៖

- វិធីសាស្ត្របុរាណលេខន៍៖ ប្រើប្រាស់លក្ខណៈតួអក្សរ សម្រាប់ប្រៀបធៀប ទៅនឹងសិលាចារឹកដទៃនៅឯស្រុកឥណ្ឌា។
- វិធីសាស្ត្រភាសា៖ ពិនិត្យសង្កេតលើការប្រើប្រាស់ភាសា នៅក្នុងសិលាចារឹក វ៉ូកាញ់ ដោយប្រៀបធៀបទៅនឹងសិលាចារឹកភាសាសំស្ក្រឹតដទៃទៀតនៅឯ ស្រុកឥណ្ឌា។
- រចនាបថភាសា៖ សង្កេតលើបទកំណាព្យក្នុងសិលាចារឹកវ៉ូកាញ់ ប្រៀបធៀប ទៅនឹងវត្ថុមានសិលាចារឹកដែលប្រើបទកំណាព្យដូចគ្នានោះនៅឥណ្ឌា។
- វាក្យសព្ទ៖ ពិនិត្យលើវាក្យសព្ទ ដោយប្រៀបធៀបវត្ថុមានពាក្យទាំងនោះ លេចឡើងនៅក្នុងសិលាចារឹកនៅឥណ្ឌា។
- ឥទ្ធិពលវប្បធម៌និងភូមិសាស្ត្រ៖ ពិនិត្យទៅលើឥទ្ធិពលវប្បធម៌ដែលមាននៅ ក្នុងសិលាចារឹក ដោយភ្ជាប់នឹងលក្ខណៈភូមិសាស្ត្រនយោបាយ ព្រមទាំង ភ្ជាប់ទៅនឹងកត្តាផ្សេងៗខាងលើ ដើម្បីកំណត់អាយុកាលសិលាចារឹក។
- ប្រៀបធៀបជាមួយកំណត់ត្រាចិន៖ ប្រៀបធៀបឈ្មោះក្នុងសិលាចារឹកវ៉ូ កាញ់ ជាមួយកំណត់ត្រារបាយការណ៍ចិន។

### ៤.១- ការប្រើប្រាស់វិធីសាស្ត្របុរាណលេខន៍

អ្នកស្រាវជ្រាវកន្លងមក ដ្បិតតែប្រើវិធីសាស្ត្រដូចគ្នាក្តី ក៏ការកំណត់អាយុកាល សិលាចារឹកនេះ មានភាពខុសប្លែកគ្នាដែរ គឺអាស្រ័យទៅលើគស្តុតាងដែលយកមកប្រៀប ធៀបៗ អ្នកស្រាវជ្រាវដំបូងគឺលោក **អាបែល ប៊ែរហ្គេញ** បានសន្និដ្ឋានជាដំបូងថាសិលា

*ចារឹកនេះយ៉ាងហោចណាស់មានអាយុកាលនៅស.វ.ទី៣*[១៣] *និងក្រោយមកទៀតលោកបានប្រៀបធៀបជាមួយសិលាចារឹកនៅរុទ្រទាម័នជាដើម ដែលមានអាយុកាលរវាងស.វ.ទី១ ដូច្នេះ លោកក៏បានកំណត់កាលបរិច្ឆេទជាថ្មី ថាស្ថិតនៅរវាងស.វ.ទី១និងទី២*[១៤]*។ លោកយល់ថាអក្សរនេះ មានឥទ្ធិពលមកពីឥណ្ឌាភាគខាងត្បូង។ លោក* ***ហ្សង់ ហ្វីលីយ៉ូហ្សាត់***[១៥] *យល់ស្របទៅនឹងសំណើនេះ។*

*ក្រោយមក លោក* ***ល្វី ហ្វីណូត់***[១៦] *និងឯលោក* ***រ៉ាមេស ចន្រ្ទ ម៉ាជូមដារ***[១៧] *បានកំណត់អាយុកាលឡើងវិញថាស្ថិតនៅចន្លោះរវាងស.វ.ទី២និងទី៣ ដោយផ្អែកលើភាពចំណាស់នៃតួអក្សរ។ នៅឆ្នាំ១៩៣២ លោក ម៉ាជូមដារ*[១៨] *ថាសិលាចារឹកនេះមិនចាស់ជាងស.វ.ទី៣ទេ និងលើកមតិផ្ទុយពីអ្នកស្រាវជ្រាវមុនៗ ដ្បិតលោកយល់ថាអក្សរក្នុងសិលាចារឹកវ៉ូកាញ់ ដូចនឹងអក្សររបស់អាណាចក្រគុសាន់នៃតំបន់កណ្ដាលនៃឥណ្ឌាភាគខាងជើង ដោយសំអាងលើសៀវភៅបុរាណលេខន៍ឥណ្ឌា* (Indische Paläographie) *របស់លោក* ***ប៊ូហ្លែរ*** **(Bühler)***។ ប៉ុន្តែលោក* ***នីលកណ្ឋ សាស្រ្តី***[១៩] *បានបដិសេធនឹងសំណើថ្មីនេះ និងគាំទ្រសម្មតិកម្មអ្នកស្រាវជ្រាវមុនៗ និងថាអក្សរនោះមានទម្រង់ជាអក្សរបល្លវៈ។ លោក* **Bahadur Chand Chhabra**[២០] *បន្តអះអាងថាតួអក្សរនេះជាប្រភេទអក្សរបល្លវៈ-គ្រន្ថៈ ដែលអាចកំណត់អាយុកាលនៅរវាងស.វ.ទី២ដល់ស.វ.ទី៤។ ឯលោក* ***ហ្សឺក សេដែស***[២១] *ក៏យល់*

---

[១៣] Abel Bergaigne, *L'ancien royaume de Campā, dans l'Indo-Chine, d'après les inscriptions* (Imp. Nationale, 1888).

[១៤] Bergaigne, *Inscriptions Sanscrites de Campa et du Cambodge*.

[១៥] Jean Filliozat, "L'inscription dite 'de Vo-çanh'", *Bulletin de l'École française d'Extrême-Orient* 55, no. 1 (1969): 107–16, https://doi.org/10.3406/befeo.1969.4856.

[១៦] Louis Finot, "Notes d'épigraphie", *Bulletin de l'École française d'Extrême-Orient* 2, no. 1 (1902): 185–91, https://doi.org/10.3406/befeo.1902.1119; Finot, "Notes d'épigraphie", 1915.

[១៧] Ramesh Chandra Majumdar, *Ancient Indian colonies in the far East*, vol. 1 (Punjab Sanskrit Book Depot, 1927).

[១៨] Ramesh Chandra Majumdar, "La paléographie des inscriptions du Champa", *Bulletin de l'École française d'Extrême-Orient* 32, no. 1 (1932): 127–39, https://doi.org/10.3406/befeo.1932.4550.

[១៩] Kallidaikurichi Aiyah Nilakanta Sastri, "L'origine de l'alphabet du Champa", *Bulletin de l'École française d'Extrême-Orient* 35, no. 2 (1935): 233–41, https://www.persee.fr/doc/befeo_0336-1519_1935_num_35_1_3945.

[២០] Bahadur Chand Chhabra, *Expansion of Indo-Aryan Culture During Pallava Rule (as Evidenced by Inscriptions)* (Munshi Ram Manohar Lal, 1965).

[២១] George Cœdès, "Les États Hindouisés d'Indochine et d'Indonésie, de Boccard", *Paris (édition revue et mise à jour)*, 1964.

*អត្ថបទដោយ៖ ហ៊ិន ឈុនតេង*

អរិយធម៌ខ្មែរ KHMER CIVILIZATION

*ថាអក្សរសិលាចារឹកនេះស្ថិតនៅក្នុងស.វ.ទី៣ ខណៈលោក* ***កមលេស្វរ ភដ្ដាចារ្យ***[២២] *យល់ថាស្ថិតនៅក្នុងស.វ.ទី៤វិញ។ មិនបញ្ចប់ត្រឹមនេះទេ លោក* ***អាហ្មាទ ហាសាន់ ដានី***[២៣] *បានរុញកាលបរិច្ឆេទសិលាចារឹកនេះទៅរវាងចុងស.វ.ទី៤និងដើមស.វ.ទី៥ ដោយពន្យល់ថាអក្សរមានលក្ខណៈចម្រុះគ្នារវាងអក្សរឥណ្ឌាភាគខាងជើងនិងភាគខាងត្បូង ប៉ុន្តែមានលក្ខណៈដូចគ្នានឹងអក្សរភាគខាងលិចច្រើនជាង គឺដូចអក្សរនៅតំបន់គុជរាតនិងខ្ពង់រាបមល្វៈ។ គំនិតនេះ* ***ម៉ៃឃើល វីកឃើរី***[២៤] *យល់ស្របតាម និងបន្តគាំទ្រដោយលោក* ***អង់តួន ហ្សាខារ៉ូវ***[២៥] *ដែរ។*

*ដូច្នេះជាសរុបមក ការកំណត់អាយុកាលរបស់សិលាចារឹកវ៉ូកាញ់ ផ្អែកលើលក្ខណៈបុរាណលេខន៍ ឬរូបរាងតួអក្សរ តាមរយៈការប្រៀបធៀបទៅនឹងសិលាចារឹកនៅឥណ្ឌាមិនទាន់ដាច់ស្រេចជ្រះស្រឡះនៅឡើយទេ។ ការសិក្សាថ្មីៗ បានរុញអាយុកាលសិលាចារឹកនេះពីស.វ.ទី២-៣ ខិតមករកអាយុកាលរវាងចុងស.វ.ទី៤ និងដើមស.វ.ទី៥វិញ។*

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

---

[២២] Kamaleswar Bhattacharya, “Précisions sur la paléographie de l’inscription dite de Võ-cạnh”, *Artibus Asiae* 24, no. 3/4 (1961): 219–24.

[២៣] Ahmad Hasan Dani, *Indian Palaeography* (Clarendon Press, 1963).

[២៤] Michael Vickery, “Funan reviewed: Deconstructing the ancients”, *Bulletin de l’Ecole française d’Extrême-Orient*, 2003, 101–43.

[២៥] Zakharov, “A Note on the Date of the Vo-canh Stele”.

# បញ្ជីឯកសារ


ប៉ាង ខាត់. *ពុទ្ធសាសនា ២៥០០*. ពុទ្ធសាសនបណ្ឌិត្យ. ពុទ្ធសាសនបណ្ឌិត្យ, ១៩៥៧។

"Bảo tàng Lịch sử Quốc gia". Accessed 27 November 2025. https://baovatquocgia.baotangso.com/bao-vat/bia-vo-canh.

Bergaigne, Abel. *Inscriptions Sanscrites de Campa et du Cambodge*. Imprimerie nationale, 1893.

Bergaigne, Abel. *L'ancien royaume de Campā, dans l'Indo-Chine, d'après les inscriptions*. Imp. Nationale, 1888.

Bhattacharya, Kamaleswar. "Précisions sur la paléographie de l'inscription dite de Võ-cạnh". *Artibus Asiae* 24, no. 3/4 (1961): 219–24.

Chhabra, Bahadur Chand. *Expansion of Indo-Aryan Culture During Pallava Rule (as Evidenced by Inscriptions)*. Munshi Ram Manohar Lal, 1965.

Cœdès, George. "Les États Hindouisés d'Indochine et d'Indonésie". *Paris (édition revue et mise à jour)*, 1964.

Dani, Ahmad Hasan. *Indian Palaeography*. Clarendon Press, 1963.

Filliozat, Jean. "L'inscription dite 'de Vo-çanh'". *Bulletin de l'École française d'Extrême-Orient* 55, no. 1 (1969): 107–16. https://doi.org/10.3406/befeo.1969.4856.

Finot, Louis. "Notes d'épigraphie". *Bulletin de l'École française d'Extrême-Orient* 2, no. 1 (1902): 185–91. https://doi.org/10.3406/befeo.1902.1119.

Finot, Louis. "Notes d'épigraphie". *Bulletin de l'École française d'Extrême-Orient* 15, no. 1 (1915): 1–135. https://doi.org/10.3406/befeo.1915.5229.

Glover, Ian, and Peter S Bellwood. *Southeast Asia: from Prehistory to History*. Psychology Press, 2004.

Jacques, Claude. "Notes sur la stèle de Vo-çanh". *Bulletin de l'École française d'Extrême-Orient* 55, no. 1 (1969): 117–24. https://doi.org/10.3406/befeo.1969.4857.

Karl-Heinz, Golzio. *Inscriptions of Campa*. Berichte Aus Der Orientalistik. Shaker Verlag, 2004.

Majumdar, Ramesh Chandra. *Ancient Indian colonies in the far East*. Vol. 1. Punjab Sanskrit Book Depot, 1927.

Majumdar, Ramesh Chandra. "La paléographie des inscriptions du Champa". *Bulletin de l'École française d'Extrême-Orient* 32, no. 1 (1932): 127–39. https://doi.org/10.3406/befeo.1932.4550.

Nilakanta Sastri, Kallidaikurichi Aiyah. "L'origine de l'alphabet du Champa". *Bulletin de l'École française d'Extrême-Orient* 35, no. 2 (1935): 233–41. https://www.persee.fr/doc/befeo_0336-1519_1935_num_35_1_3945.

Vickery, Michael. "Funan reviewed: Deconstructing the ancients". *Bulletin de l'Ecole française d'Extrême-Orient*, 2003, 101–43.

Zakharov, Anton O. "A Note on the Date of the Vo-canh Stele". *South East Asian Review* 35 (2010): 17–21.


អត្ថបទដោយៈ ហ៊ុន ឈុនតេង

# បញ្ជីរូបភាព



សិលាចារឹកវ៉ូកាញ់

ប្រភពរូបភាព៖ https://en.wikipedia.org/wiki/V%C3%B5_C%E1%BA%A1nh_inscription#/media/File:Vo_Canh_stele_(National_Museum_of_Vietnamese_History).jpg

អត្ថបទដោយ៖ ហ៊ុន ឈុនតេង





សិលាចារឹកវ៉ូកាញ់

ប្រភពរូបៈ https://redsvn.net/chum-anh-bia-vo-canh-bao-vat-2-000-nam-cua-vuong-quoc-champa2/

អត្ថបទដោយៈ ហ៊ុន ឈុនតេង





សិលាចារឹកវ៉ូកាញ់

ប្រភពរូប៖ https://redsvn.net/chum-anh-bia-vo-canh-bao-vat-2-000-nam-cua-vuong-quoc-champa2/

អត្ថបទដោយ៖ ហ៊ុន ឈុនតេង